# **អារម្ភកថា**

ក្នុងរបបកម្ពុជាប្រជាធិបតេយ្យពីឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៧៩ ពួកខ្មែរក្រហមបានបង្កើតមន្ទីរឃុំឃាំង និងវាលពិឃាតជាច្រើនកន្លែងនៅទូទាំងប្រទេសកម្ពុជា។ ដោយឡែកនៅក្រុងភ្នំពេញ ពួកប៉ុលពតបានបង្កើតមជ្ឈមណ្ឌលសន្តិសុខដ៏ធំជាងគេនៅកម្ពុជាឈ្មោះថា "មន្ទីរសន្តិសុខស.២១" ។ ពួកនេះបានបញ្ជូនជនរងគ្រោះដែលពួកវាចាត់ទុកជាអ្នកទោសសំខាន់ៗពីមន្ទីរឃុំឃាំងនានាជាច្រើនកន្លែងនៅក្នុងផ្ទៃប្រទេសមកកាន់មន្ទីរឃុំឃាំង"មន្ទីរសន្តិសុខស.២១" ដើម្បីសួរចម្លើយ ហើយកំទេចចោល(សម្លាប់)នៅឯមណ្ឌលពិឃាតជើងឯក ។

ជើងឯកជាឈ្មោះឃុំមួយក្នុងខណ្ឌដង្កោរាជធានីភ្នំពេញស្ថិតនៅចំងាយ១៥គីឡូម៉ែត្រប៉ែកនិរតីរាជធានីភ្នំពេញ។ ក្នុងឆ្នាំ១៩៧៥ ពួកខ្មែរក្រហមបានរៀបចំមណ្ឌលពិឃាតជើងឯកនេះ នៅលើផ្ទៃដីពីរហិកតាឲ្យទៅជាមណ្ឌលពិឃាតដ៏សាហាវព្រៃផ្សៃយង់ឃ្នងបំផុត។ ចាប់ពីឆ្នាំ១៩៧៦ ដល់ដំណាច់ឆ្នាំ១៩៧៨ ជនរងគ្រោះនៅគុកទួលស្លែងប្រមាណជាងមួយម៉ឺននាក់ក្នុងនោះមានបញ្ញវន្ត អគ្គទូត ជនបរទេស ស្ត្រី និងកុមារ...។ល។ ត្រូវបានបញ្ជូនដោយសម្ងាត់ និងដោយបង្ខំមកសម្លាប់នៅមណ្ឌលពិឃាតជើងឯកនេះទាំងដៃជាប់ចំណង និងក្រណាត់រុំភ្នែក ក្នុងនោះមានជនបរទេសចំនួន៩នាក់ផងដែរ ពិសេសនៅដើមខែឧសភាឆ្នាំ១៩៧៨ កម្មាភិបាល ទាហានប៉ុលពត និងប្រជាជនដែលពួកវាបានចោទថាក្បត់នៅភូមិភាគបូព៌ា និងជាទីភ្នាក់ងារស៊ើបការណ៍របស់អង្គការអន្តរជាតិមួយចំនួនដូចជា CIA ឬ KGB ជាដើម ។

ក្រោយថ្ងៃជ័យជំនះ៧ មករា ឆ្នាំ១៩៧៩ គឺដើមឆ្នាំ១៩៨១ យើងបានរកឃើញមណ្ឌលពិឃាតនេះ មានរណ្តៅសាកសពសរុប១២៩ ព្រមទាំងបានគាស់រួច៨៦រណ្តៅ មានសាកសពចំនួន៨៩៨៥។ ក្រោមការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាល អដ្ឋិធាតុដែលប្រមូលបានពីការគាស់រណ្តៅ ត្រូវបានយកមកទុកបណ្តោះអាសន្ននៅរោងឈើប្រក់ស័ង្កសីមួយ។ ដើមឆ្នាំ១៩៨៨ អដ្ឋិធាតុទាំងនោះត្រូវបានដុសលាងសំអាតនិងអភិរក្សដោយគ្រូពេទ្យជំនាញវៀតណាមទន្ទឹមនឹងនោះ ស្តូបមួយត្រូវបានសាងសង់ឡើងដើម្បីតម្កល់ទុកនូវអដ្ឋិធាតុ ដែលបានលាងសំអាតរួច ហើយបានប្រែក្លាយទៅជាមជ្ឈមណ្ឌលភស្តុតាងពិសេសនៃរបបប្រល័យពូជសាសន៍ និងជាមជ្ឈមណ្ឌលជាតិសំរាប់ឧទ្ទិសវិញ្ញាណក្ខន្ធដល់ជនរងគ្រោះដែលបានស្លាប់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យខ្មែរក្រហម ។

រយៈពេល១៧ឆ្នាំ (ឆ្នាំ ១៩៨៨ ដល់ ២០០៥) សាលារាជធានីភ្នំពេញទទួលបានការអនុញ្ញាតពីរាជរដ្ឋាភិបាលឲ្យស្វែងរកដៃគូឯកទេសដើម្បីអភិរក្ស និងថែរក្សាទីតាំងមជ្ឈមណ្ឌលពិឃាតនេះឲ្យបានគង់វង្សចីរកាល និងស្របទៅតាមបច្ចេកវិទ្យានៃសារមន្ទីរវិទ្យាសាស្ត្ររបស់ជាតិ។ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ២០០៥ កិច្ចសន្យាសម្បទានមួយរវាងសាលាក្រុងភ្នំពេញ និងក្រុមហ៊ុនជេស៊ីរ៉ូយ៉ាល់ ខមភេនី អិលធីឌី បានព្រមព្រៀងឡើង។ យោងតាមកិច្ចសន្យា និងយោងទៅលើភាពជាក់ស្តែងនៃការវិវត្ត ប្រែពណ៌ខុសពីមុនរបស់អដ្ឋិធាតុទាំងអស់ និងសភាពរបកជាអន្ទើៗដែលឈានទៅរកការពុកផុយនោះចាំបាច់តម្រូវឲ្យមានការអភិរក្សសារជាថ្មីឡើងវិញ។ កិច្ចការទាំងនេះមានការចុះអង្កេតនិងវាយតម្លៃជាក់ស្តែងពីមន្ត្រីឯកទេសក្រសួងវប្បធម៌និងវិចិត្រសិល្បៈ, មន្ត្រីសាលារាជធានីភ្នំពេញ, និងបុគ្គលិកមជ្ឈមណ្ឌលប្រល័យពូជសាសន៍ជើងឯក ។

ក្រោយពីការវាយតម្លៃពីមន្ត្រីជំនាញទាំងបីស្ថាប័នរួចមក **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានផ្តល់ជាគោលការណ៍ឲ្យ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ធ្វើការអភិរក្សនិងជួសជុលស្តូបតម្កល់ និងអដ្ឋិធាតុទាំងអស់ដើម្បីជៀសវាងការខូចខាត ឬបាត់បង់ភស្តុតាងនៃរបបវាលពិឃាត។ បន្ទាប់ពីបានគោលការណ៍ពីរាជរដ្ឋាភិបាល ក្រសួងវប្បធម៌និងវិចិត្រសិល្បៈបានរិះរកមធ្យោបាយ និងបច្ចេកទេសតាមបែប

វិទ្យាសាស្ត្រទំនើប ដើម្បីអភិរក្សទប់ស្កាត់ការពុកផុយ ហើយរក្សាឲ្យបាននូវភស្តុតាងទាំងអស់នេះៗ ក្រោយមកគណៈកម្មការមួយត្រូវបានបង្កើតឡើង ដែលមានសមាសភាពពីមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ មន្ត្រីសាលារាជធានីភ្នំពេញ, និងបុគ្គលិកមជ្ឈមណ្ឌលប្រល័យពូជសាសន៍ជើងឯក ដើម្បីធ្វើការវាយតម្លៃនិងត្រួតពិនិត្យលើកិច្ចការអភិរក្សៗ ចំណែកឯអនុគណៈកម្មការបច្ចេកទេស មានសមាសភាពចូលរួមពី មន្ត្រីជំនាញនៃក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ព្រមទាំងបុគ្គលិករបស់មជ្ឈមណ្ឌលប្រល័យពូជសាសន៍ជើងឯក ដើម្បីប្រតិបត្តិការងារផ្ទាល់ជាប្រចាំៗ ការអភិរក្សត្រូវបានអនុវត្តតាមដំណាក់កាលនៃបច្ចេកទេសសំដៅថែរក្សាឲ្យបាននូវអដ្ឋិធាតុ និងភស្តុតាងផ្សេងៗទៀតដែលមាននៅក្នុងមជ្ឈមណ្ឌលប្រល័យពូជសាសន៍ជើងឯកៗ

ក្រុមការងារបានអនុវត្តការអភិរក្សនេះជា៣ដំណាក់កាលៈ ដំណាក់កាលទី១ ពីខែសីហា ឆ្នាំ២០១៣ ដល់ខែសីហា ឆ្នាំ២០១៤ ការអភិរក្សអដ្ឋិធាតុដែលមានសភាពខូចខាតធ្ងន់ធ្ងរៗ ដំណាក់កាលទី២ ពីខែសីហា ឆ្នាំ២០១៤ ដល់ខែសីហា ឆ្នាំ២០១៥ ជាការអភិរក្សអដ្ឋិធាតុដែលមានសភាពខូចខាតមធ្យម និងដំណាក់កាលទី៣ ពីខែសីហា ឆ្នាំ២០១៥ ដល់ខែសីហា ឆ្នាំ២០១៦ ការអភិរក្សអដ្ឋិធាតុដែលមានសភាពខូចខាតដោយការប្រែប្រួលខុសពីលក្ខណៈដើមតិចតួចៗ មុនពេលធ្វើការអភិរក្សក្រុមការងារបានត្រួតពិនិត្យនិងការវិភាគរកស្លាកស្នាមធ្វើទារុណកម្មឬស្លាកស្នាមនៃការសម្លាប់ដោយប្រើឧបករណ៍ផ្សេងៗ ទៅលើជនរងគ្រោះ និងថតរូបភាពទុកជាឯកសារដោយផ្តល់អត្តសញ្ញាណដល់អដ្ឋិធាតុនៃជនរងគ្រោះនីមួយៗ ចុះក្នុងបញ្ជីសារពើភណ្ឌតាមប្រព័ន្ធព័ត៌មានវិទ្យា ហើយចងក្រងជាសៀវភៅកាតាឡុកៗ ក្រុមការងារក៏បានសហការ និងទទួលការបណ្តុះបណ្តាលបន្ថែមពីអ្នកជំនាញមកពីសហរដ្ឋអាមេរិក Central identification laboratory of Department of Defense, United State of America, សាកលវិទ្យាល័យ Oxford នៃប្រទេសអង់គ្លេស, សាកលវិទ្យាល័យ Otago នៃប្រទេសណូវែលសេឡង់ និងអ្នកឯកទេសដែលធ្វើការអភិរក្សការប្រល័យពូជសាសន៍នៅប្រទេស Kosovo មកពីសាកលវិទ្យាល័យ LMU-Munich នៃប្រទេសអាល្លឺម៉ង់ និងអ្នកឯកទេសក្នុងស្រុកៗ ដូចនេះដំណើរការអភិរក្សបានប្រព្រឹត្តទៅដោយរលូនតាមគម្រោងដែលបានគ្រោងទុកៗ ក្រោយពេលអភិរក្សគណៈកម្មការបានវាយតម្លៃជាផ្លូវការថាលទ្ធផលការងារដែលបានអនុវត្តកន្លងមកមានគុណភាពខ្ពស់ត្រឹមត្រូវតាមស្តង់ដារអាចរក្សាទុកសម្រាប់រយៈពេលយូរបន្តទៅទៀតបាន ៕

| | |
|---|---|
| **គណៈកម្មការអភិរក្សអដ្ឋិធាតុ** | **មជ្ឈមណ្ឌលប្រល័យពូជសាសន៍ជើងឯក** |
| ប្រធាន | អនុប្រធាន |
| **ហាប់ ទូច** | **សេ សុភាវិចី** |
| **រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ** | **អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ ៤** |
| **ភឿង សកុណា** | **ប៉ា សុជាតិវង្ស** |